Equal Access and Opportunities for Students and Educators

**Equity & Civil Rights**

PROMOTING EDUCATIONAL EXCELLENCE FOR ALL

# យល់ដឹងអំពីនីតិវិធីនៃការប្តឹងតវ៉ាទៅនឹងការរើសអើង ដែលមិនស្របតាមច្បាប់ នៅមណ្ឌលសាលារៀនរបស់អ្នក ។

ការិយាល័យនាយកទទួលបន្ទុកកិច្ចការណែនាំសាធារណៈ (OSPI) គឺជាអង្គភាព ដែលទទួលខុសលើការត្រួតពិនិត្យការអប់រំសាធារណៈ កម្រិត K-12 នៅរដ្ឋវ៉ាស៊ីង តោន ។ នៅការិយាល័យ OSPI ផ្នែកសមធមិ និង សិទ្ធិពលរដ្ឋ ផ្តល់ជំនួយបច្ចេកទេស ដល់មណ្ឌលសាលារៀន ឪពុកម្តាយ និង សិស្សានុសិស្ស ក្នុងការដោះស្រាយបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់រដ្ឋនិងសហព័ន្ធ ស្តីពីការមិនរើសអើង ។

## តើអ្វីទៅជា "ការរើសអើង"?

ការរើសអើងគឺជាការចាតទុកជនណាម្នាក់ ឬ មនុស្សមួយក្រុម ដោយមិនត្រឹមត្រូវ និង ដោយមិនស្មើភាព ដោយសារតែពួកគេ គឺជាផ្នែកមួយនៃក្រុមមនុស្សដែល ត្រូវបានគេកំណត់យ៉ាងច្បាស់លាស់ គឺថ្នាក់រៀនមានការការពារ ។ ការរើសអើងអាចកើតឡើង នៅពេលដែលជនម្នាក់ត្រូវបានចាត់ទុកថាខុសពីគេ ឬ ត្រូវបានបដិសេធមិនឱ្យចូលរួមកម្មវិធី សេវាកម្ម ឬ សកម្មភាព ផ្សេងៗ ដោយសារតែពួកគេគឺជា ផ្នែកមួយនៃថ្នាក់រៀនមានការការពារ ។ ការរើសអើងក៏អាចកើតមានឡើង នៅពេលដែល សាលារៀនមួយ ឬមណ្ឌលសាលារៀនមួយមិនបានដោះស្រាយបញ្ហាអសមត្ថភាពរបស់សិស្ស ឬ បុគ្គលិក ។

ការយាយី (ផ្អែកលើថ្នាក់រៀនមានការការពារ) និង ការយាយីផ្លូវភេទ អាចជាទម្រង់ នៃការរើសអើង នៅពេលដែលការយាយី នោះបង្កើតចេញជាបរិស្ថានអរិភូត ។

## តើអ្វីទៅជាថ្នាក់រៀនមានការការពារ?

ថ្នាក់រៀនមានការការពារគឺជាក្រុមមនុស្សដែលចែករំលែកចរិកលក្ខណៈរួម និង ត្រូវបានការពារពីការរើសអើងនិងការយាយី ដោយច្បាប់សហព័ន្ធ និងរដ្ឋ ។ ថ្នាក់រៀនមានការការពារដែលត្រូវបានកំណត់ដោយច្បាប់រដ្ឋវ៉ា ស៊ីងតោនរួមមាន :

- ភេទ
- អម្បូរ/ពណ៌សម្បុរ
- ជំនឿ/សាសនា
- ជាតិសាសន៍
- អសមត្ថភាព ឬ ការប្រើប្រាស់សត្វឆ្កែដែលមានការបង្ហាត់ជាអ្នកនាំផ្លូវ ឬ សត្វចេះធ្វើការ
- ការបង្ហាញផ្នែកភេទ ដូចជា ការបញ្ចេញយេនឌ័រ ឬ អត្តសញ្ញាណយេនឌ័រ
- ស្ថានភាពជាយុទ្ធជនឬយោធាបញ្ចប់កាតព្វកិច្ចដោយមានកិត្តិយស





## តើខ្ញុំគួរធ្វើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំជឿជាក់ថា កូនរបស់ខ្ញុំកំពុងត្រូវបានគេរើសអើង?

អ្នកត្រូវបានសំដែងចេញនូវក្តីកង្វល់របស់អ្នកទៅកាន់គ្រូបង្រៀនកូនរបស់អ្នក ឬ នាយកសាលាភ្លាមៗ! ការធ្វើបែបនេះនឹងជួយដល់សាលារៀនក្នុងការឆ្លើយតបទៅនឹងស្ថានភាពនោះ បានលឿនតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ក្នុងករណីអ្នកមិនអាចជួបជាមួយគ្រូបង្រៀនឬនាយកសាលាទេ អ្នកអាចទាក់ទង ទៅការិយាល័យកណ្តាលនៃមណ្ឌលសាលារៀនរបស់អ្នក ។ មណ្ឌលសាលារៀន នីមួយៗនឹងចាត់ឱ្យនរណាម្នាក់ដែលទទួលខុសត្រូវលើការដោះស្រាយបណ្តឹងតវ៉ាទៅនឹងការរើសអើង បំពេញភារកិច្ច ។

ជួនកាល បុគ្គលនេះត្រូវបានគេហៅថា អ្នកសម្របសម្រួល IX ឬ អ្នកសម្រប សម្រួលផ្នែក 504 សម្រាប់បញ្ហាទាំងឡាយដែលទាក់ទងនឹងអសមត្ថភាព ។

នៅពេលដែលបញ្ហាមួយមិនអាចត្រូវបានដោះស្រាយនៅក្នុងអង្គប្រជុំ អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅមណ្ឌលសាលារៀននោះ ។

អ្នកក៏មានសិទ្ធិទំនាក់ទំនងអង្គភាពខាងក្រោម នៅពេលណាក៏បាន ដើម្បីស្នើសុំការសើបអង្កេតអំពីសំដីអះអាងរបស់អ្នកអំពីការរើសអើង :

**ការិយាល័យសិទ្ធិមនុស្ស ក្រសួងអប់រំសហរដ្ឋអាមេរិក**

លេខ 915 វិថីទីពីរ បន្ទប់ 3310

ទីក្រុងស៊ីអាថល WA 98174-1099

(206) 607-1600 / TDD: (877) 521-2172

www2.ed.gov/about/offices/list/ocr

**គណៈកម្មការសិទ្ធិមនុស្ស រដ្ឋវ៉ាស៊ីងតោន**

ប្រអប់ប្រៃសណីយ៍លេខ 42490

រដ្ឋធានី អូលីមព្យ៉ា WA 98504-2490

(360) 753-6770 / Toll Free: (800) 233-3247 / TTY: (800) 300-7525

www.hum.wa.gov

## ចុះប្រសិនបើខ្ញុំមិនអាចដោះស្រាយបញ្ហា ជាមួយនឹងសាលារៀនវិញ?

ប្រសិនបើអ្នកមិនអាចដោះស្រាយក្តីកង្វល់របស់អ្នក អ្នកអាចដាក់ពាក្យបណ្តឹងតវ៉ា ទៅមណ្ឌលសាលារៀនបាន ។

### អ្នកណាក៏អាចដាក់ពាក្យបណ្តឹងតវ៉ាទៅ មណ្ឌលសាលារៀនបានដែរ

អ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាជាផ្លូវការ ដោយសរសេរលិខិតមួយច្បាប់ ផ្ញើទៅនាយកសាលារៀន ***ដែលលិខិតនោះពិពណ៌នាអំពីអ្វីដែលបានកើតឡើង និងមូលហេតុដែលអ្នកគិតថា វាជាការរើសអើង ។*** បញ្ជាក់បន្ថែម នូវអ្វីដែលអ្នកចង់ឱ្យមណ្ឌលធ្វើក៏បានកាន់តែប្រសើរ ។ លិខិតរបស់អ្នកត្រូវតែមានចុះហត្ថលេខា ។

### តើមណ្ឌលនឹងធ្វើអ្វីខ្លះ?

បុគ្គលិកដែលចាត់តាំងដោយមណ្ឌល ឱ្យទទួលពាក្យបណ្តឹងតវ៉ា នឹងសើបអង្កេតលើការអះអាងរបស់អ្នក និង ផ្តល់ដល់នាយកសាលារៀននូវឯកសាររបាយការណ៍ទាក់ទងនឹងពាក្យបណ្តឹងតវ៉ានោះ ព្រមទាំងលទ្ធផលនៃការអង្កេតនោះផងដែរ ។ អ្នកនិងមណ្ឌលក៏អាចឯកភាពគ្នាក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់អ្នក នៅក្នុងករណីនៃការស៊ើបអង្កេត ។

### តើនាយកសាលារៀននឹងធ្វើអ្វីខ្លះ?

នាយកសាលារៀននឹងផ្ញើលិខិតមួយច្បាប់ទៅអ្នក រយៈពេល 30 **ថ្ងៃតាមប្រតិទិន** ។ លិខិតនោះនឹងបដិសេធការអះអាងរបស់អ្នក ឬពិពណ៌នាអំពីវិធានការសមស្របដែលមណ្ឌលបានអនុវត្ត ។ លិខិតនោះនឹងមានបញ្ជាក់អំពីនីតិវិធីនៃការប្តឹងសារទុក្ខ ទៅគណៈនាយកសាលារៀន ក្នុងករណីអ្នកមិនយលស្របនឹងសេចក្តីសម្រេចរបស់ នាយកសាលារៀនទេ ។

វិធានការកែតម្រូវត្រូវតែមានរយៈពេលមិនលើសពី 30 **ថ្ងៃតាមប្រតិទិន** គិតពីកាលបរិច្ឆេទនៃលិខិតរបស់នាយកសាលារៀន ។

## ចុះបើខ្ញុំមិនឯកភាពនឹងសេចក្តីសម្រេចរបស់នាយកសាលារៀន ឬ មិនមាននរណាឆ្លើយតបនឹងលិខិតរបស់ខ្ញុំវិញ?

ដំណាក់កាលបន្ទាប់របស់អ្នកគឺប្តឹងសារទុក្ខទៅគណៈនាយកសាលារៀន ។

### តើអ្វីទៅជាបណ្តឹងសារទុក្ខ?

បណ្តឹងសារទុក្ខគឺជាសំណើសុំធ្វើការកែសេចក្តីសម្រេចផ្លូវការ ។

### តើខ្ញុំប្តឹងសារទុក្ខទៅគណៈនាយកសាលារៀន តាមនីតិវិធីដូចម្តេចខ្លះ?

អ្នកអាចប្តឹងសារទុក្ខ ដោយសរសេរខិតមួយច្បាប់ផ្ញើជូនគណៈនាយកសាលារៀន ។ លិខិតនោះត្រូវតែបញ្ជាក់ផ្នែកណាមួយនៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់នាយកសាលារៀន ដែលអ្នកចង់ប្តឹងសារទុក្ខ និង ចង់ឱ្យមណ្ឌលធ្វើ ។

លិខិតរបស់អ្នកត្រូវតែដាក់តាមរយៈលេខាធិការនៃគណៈនាយកសាលារៀន ត្រឹមរយៈពេល 10 **ថ្ងៃតាមប្រតិទិន** បន្ទាប់ពីអ្នកបានទទួលលិខិតឆ្លើយតបរបស់នាយកសាលារៀន ។

### តើគណៈនាយកសាលារៀននឹងធ្វើអ្វីខ្លះ?

គណៈនាយកសាលារៀននឹងរៀបចំពេលវេលាធ្វើសវនាការមួយ ក្នុងរយៈពេល 20 **ថ្ងៃតាមប្រតិទិន** បន្ទាប់ពីពួកគេទទួលលិខិតបណ្តឹងសារទុក្ខរបស់អ្នក ។ អ្នកក៏អាចឯកភាពលើកាលបរិច្ឆេទផ្សេងទៀតផងដែរ ។

### តើនឹងមានអ្វីកើតឡើងខ្លះនៅឯសវនាការ?

អ្នកនឹងបកស្រាយអំពីមូលហេតុដែលអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់នាយកសាលារៀន ។ អ្នកអាចនាំយកមកនូវសាក្សី ឬ ព័តិមានផ្សេងៗទៀតដែលទាក់ទងទៅនឹងបណ្តឹងសារ ទុក្ខរបស់អ្នក ។

គណៈនាយកនឹងផ្ញើជូនអ្នកនូវសេចក្តីសម្រេចរបស់ពួកគេមួយច្បាប់ រយៈពេល 10 **ថ្ងៃតាមប្រតិទិន** បន្ទាប់ពីសវនាការចប់ ។ សេចក្តីសម្រេចនោះនឹងបញ្ជាក់អំពីនីតិវិធីនៃការប្តឹងសារទុក្ខ ទៅការិយាល័យនាយកទទួលបន្ទុកកិច្ចការណែនាំសាធារណៈ ប្រសិនបើអ្នកមិនឯកភាពទេ ។

## ចុះប្រសិនបើខ្ញុំមិនឯកភាពនឹងសេចក្តីសម្រេច របស់គណៈនាយកសាលារៀនវិញ?

អ្នកអាចប្តឹងសេចក្តីសម្រេចរបស់គណៈនាយកសាលារៀន ទៅការិយាល័យនាយកទទួលបន្ទុកកិច្ចការណែនាំសាធារណៈ (OSPI) ។

### តើខ្ញុំដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់ការិយាល័យ OSPI តាមនីតិវិធីដូចម្តេចខ្លះ?

អ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខ ដោយសរសេរលិខិតផ្ញើទៅការិយាល័យនាយកទទួលបន្ទុកកិច្ចការណែនាំសាធារណៈ ។ លិខិតនោះត្រូវតែមានផ្នែកនៃសេចក្តីសម្រេចរបស់គណៈនាយកសាលារៀនដែលអ្នកចង់ប្តឹងសារទុក្ខ និង អ្វីដែលអ្នកចង់ឱ្យមណ្ឌលធ្វើ ។

លិខិតមានចុះហត្ថលេខារបស់អ្នកត្រូវតែទទួលបានដោយការិយាល័យ OSPI ត្រឹមរយៈពេល 20 **ថ្ងៃតាមប្រតិទិន** គិតពីថ្ងៃទទួលសេចក្តីសម្រេចរបស់គណៈនាយកសាលារៀន ។ លិខិតនោះអាចត្រូវបានប្រគល់ដោយផ្ទាល់ ឬ តាមរយៈអ៊ីមែល :

ការិយាល័យ OSPI<br>
ផ្នែកសេវាកម្មធនធានរដ្ឋបាល<br>
ប្រអប់ប្រៃសណីយ៍លេខ 47200<br>
រដ្ឋធានី អូលីមព្យ៉ា WA 98504-7200<br>
លេខទូរស័ព្ទ (360) 725-6133

### តើការិយាល័យ OSPI នឹងធ្វើអ្វីខ្លះ?

ការិយាល័យ OSPI នឹងរៀបចំពេលវេលាសម្រាប់សវនាការមួយ ដោយមានចៅក្រមច្បាប់រដ្ឋបាល តាមរយៈការិយាល័យសវនាការរដ្ឋបាល (OAH) ។ ក្នុងអំឡុងពេលនៃដំណើរការនេះ អ្នកនឹងត្រូវបានផ្តល់នូវព័តិមានអំពីសវនាការនោះ ។

នៅឯសវនាការ អ្នកនឹងបកស្រាយអំពីមូលហេតុដែលអ្នកមិនឯកភាពនឹងសេចក្តីសម្រេចរបស់គណៈនាយកសាលារៀន ។ អ្នកអាចនាំយកមកនូវសាក្សី ឬ ព័តិមានផ្សេងៗទៀតដែលទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់អ្នក ។ បន្ទាប់ពីសវនាការចប់ អ្នកនឹងទទួលបានសេចក្តីសម្រេចរបស់ចៅក្រមចំនួនមួយច្បាប់ ។


ការិយាល័យសមធម៌ និង សិទ្ធិពលរដ្ឋ<br>
ការិយាល័យនាយកទទួលបន្ទុកកិច្ចការណែនាំសាធារណៈ<br>
ប្រអប់ប្រៃសណីយ៍លេខ 47200; រដ្ឋធានី អូលីមព្យ៉ា WA 98504-7200<br>
លេខទូរស័ព្ទ : (360) 725-6162 លេខទូរសារ : (360) 664-2967<br>
TTY: (360) 664-3631<br>
អ៊ីមែល : equity@k12.wa.us



ថ្ងៃទី 20 ខែ មេសា ឆ្នាំ 2011

CAMBODIAN


**សូមស្វែងយល់បន្ថែមតាមរយៈ : www.k12.wa.us/Equity**


ការិយាល័យ OSPI ផ្តល់នូវការចូលរួមដោយស្មើភាពក្នុងកម្មវិធី និង សេវាកម្មទាំងអស់ ដោយមិនមានការរើសអើងភេទ អម្បូរ ជំនឿ សាសនា ពណ៌សម្បុរ ជាតិសាសន៍ អាយុ ស្ថានភាពជាយុទ្ធជនឬយោធាបញ្ចប់កាតព្វកិច្ចដោយកិត្តិយស ការ បង្ហាញផ្នែកភេទ ដូចជា ការបញ្ចេញយេនឌ័រ ឬ អត្តសញ្ញាណយេនឌ័រ វិញ្ញាណ អសមត្ថភាពផ្នែកគំនិតប្រាជ្ញា ឬ រូបរាង្គកាយ ឬ ការប្រើប្រាស់សត្វឆ្កែដែលមានការ បង្ហាត់ជាអ្នកនាំផ្លូវឬសត្វចេះធ្វើការ ដោយបុគ្គលពិការភាព ។ សំនួរនិងបណ្តឹងតវ៉ា ទាក់ទងនឹងការរើសអើងដែលមានសេចក្តីអះអាងអាចត្រូវបានបញ្ជូនដោយផ្ទាល់ ទៅកាន់នាយកការិយាល័យសមធម៌ និង សិទ្ធិពលរដ្ឋ ដែលមានលេខទូរស័ព្ទ (360) 725-6162 ឬ ប្រអប់ប្រៃសណីយ៍លេខ 47200 រដ្ឋធានី អូលីមព្យ៉ា WA 98504 ។